ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៩ សហវ.ឧ

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៣

# សារាចរ

## ស្តីពី
## ការណែនាំអនុវត្តការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៣

ក្នុងគោលបំណងដើម្បីឱ្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ អនុវត្តបានត្រឹមត្រូវតាមច្បាប់ និង ស្មារតីនៃប្រកាសលេខ ៨៨៦ សហវ.ពដ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០០៣ ហើយនិងទទួលបានលទ្ធផលល្អប្រសើរនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំ និង កំណត់អំពីការប្រមូលពន្ធ ដូចខាងក្រោម ៖

១- ចំពោះយានយន្តដែលទើបនឹងដាក់ឱ្យធ្វើចរាចរ នៅក្នុងខែ ធ្នូ ឆ្នាំ២០០២ ហើយមានប័ណ្ណសំគាល់យានយន្តត្រឹមត្រូវចេញដោយក្រសួងឬមន្ទីរសាធារណការនិងដឹកជញ្ជូន ឬ មានបង្កាន់ដៃបង់ពន្ធនាំចូល ដែលចុះកាលបរិច្ឆេទនេះ គឺត្រូវបានអនុគ្រោះមិនឱ្យបង់ពន្ធឆ្នាំ២០០២ ឡើយ គឺត្រូវបង់ពន្ធសំរាប់ឆ្នាំ២០០៣ តែប៉ុណ្ណោះ ។

២- ចំពោះ -ទោចក្រយានយន្តគ្រប់ប្រភេទ
-កាណូតនេសាទមានកំលាំងដល់ ៥០សេះ (ផ្លូវទន្លេ)
-ទូកម៉ាស៊ីនចំហៀង "ជើងបង្កង" (ផ្លូវទន្លេ)
-ទូកនេសាទដែលមានកំលាំងសេះដល់ ២៥សេះ (ផ្លូវសមុទ្រ)
-ទូកនេសាទម៉ាស៊ីនចំហៀង(ជើងបង្កង)ដែលមានកំលាំងសេះដល់ ១៥សេះ (ផ្លូវសមុទ្រ)

ត្រូវបានអនុគ្រោះឱ្យបង់តែពន្ធសំរាប់ ឆ្នាំ២០០៣ តែប៉ុណ្ណោះ ។ ការអនុគ្រោះនេះ គឺជាការអនុគ្រោះចុងក្រោយដើម្បីជាទុនសំរាប់យានយន្តទាំងអស់នេះ មានមូលដ្ឋានក្នុងការអនុវត្តនីបង់ពន្ធនៅបណ្តាឆ្នាំខាងមុខៗទៀត ។

៣- ចំពោះ រថយន្ត កាណូត ចាស់ៗខូចទុកមិនប្រើប្រាស់ និងខកខានមិនបានបង់ពន្ធឆ្នាំមុន ហើយក្នុងឆ្នាំ២០០៣នេះ បានរៀបចំជួសជុលយកមកប្រើប្រាស់ជាថ្មី ត្រូវបានអនុគ្រោះ អនុញ្ញាតិអោយបង់តែពន្ធសំរាប់ឆ្នាំ២០០៣ ប៉ុន្តែត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់របស់ភូមិ-ឃុំ និង វិក្ក័យប័ត្ររបស់ជាងជួសជុលដែលមានអាសយដ្ឋានច្បាស់លាស់ ។

៤-សំរាប់ឆ្នាំ២០០៣នេះ ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ គឺត្រូវអនុវត្តចំពោះរថយន្តដែលមានផ្លាកលេខ និងមានប័ណ្ណសំគាល់យានយន្តត្រឹមត្រូវចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន រីឯរថយន្តពាក់ផ្លាកលេខ រាជការ..... នប.... ខម..... គឺត្រូវអនុវត្តចំពោះតែរថយន្តទាំងឡាយណាដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួងសាម៉ីតែប៉ុណ្ណោះ"។

៥-យានយន្តគ្រប់ប្រភេទ ដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០២ ហើយបានលក់ឱ្យអ្នកផ្សេង ករណីនេះត្រូវកំណត់ឱ្យបង់ពន្ធសំរាប់ឆ្នាំ២០០២ និងបង់ប្រាក់ពិន័យតាមច្បាប់ ទើបអនុញ្ញាត្តិអោយបង់ពន្ធសំរាប់ឆ្នាំ២០០៣ ។

៦-សក្ខីប័ត្រដែលត្រូវភ្ជាប់ជាមួយនិងលិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន នឹងយានជំនិះគ្រប់ប្រភេទ ដែលត្រូវរក្សាទុក ដូចជា វិក្ក័យប័ត្រឬឯកសារផ្សេងៗចេញដោយអ្នកលក់ បង្កាន់ដៃបង់ពន្ធនាំចូល ឬ ប័ណ្ណសំគាល់យានយន្ត................ត្រូវផ្តល់នូវឯកសារថតចំលងហើយមានកាមេភ្ញាក់ "បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម" ពីសាលាខ័ណ្ឌ-ស្រុក ឬ សាលាខេត្ត-ក្រុង ។

គ្រប់អង្គភាពពន្ធដារមានភារកិច្ចត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**<u>ចម្លងជូនៈ</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពពន្ធដារ
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ.កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់